ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ សរ

# សារាចរ
## ស្តីពី
## កាតព្វកិច្ចចុះផ្សាយក្នុងរាជកិច្ច

យោងតាមមាត្រា៩៣ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងមាត្រា១៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី តម្រូវឱ្យគ្រប់លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅត្រូវចុះផ្សាយក្នុងសៀវភៅរាជកិច្ច។ ទោះបីជាមានសារាចរណែនាំលេខ១២ សរណន ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីកាតព្វកិច្ចកសាងរាជកិច្ចក៏ដោយ ក៏រាជរដ្ឋាភិបាលសង្កេតឃើញថា ក្រសួង ស្ថាប័នមួយចំនួនអនុវត្តមិនទាន់បានល្អនៅឡើយ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការដូចខាងក្រោម៖

១ - គ្រប់ក្រសួង ស្ថាប័ន ត្រូវត្រួតពិនិត្យរាល់លិខិតបទដ្ឋានគតិយុត្តនានាមុនពេលថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខា ឬជូននាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នចុះហត្ថលេខា ដើម្បីចៀសវាងនូវកំហុសនានាដែលកើតឡើងជាយថាហេតុបន្ទាប់ពីចុះផ្សាយក្នុងសៀវភៅរាជកិច្ច។

២ - គ្រប់ក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្តនានា ត្រូវរួសរាន់ផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី នូវគ្រប់លិខិតបទដ្ឋានគតិយុត្តដែលមានអានុភាពអនុវត្តទូទៅឬសម្រាប់អនុវត្តទូទាំងប្រទេស ដោយមិនរាប់បញ្ចូលនូវប្រកាសរបស់ក្រសួងស្តីពីការតែងតាំងមន្ត្រីក្នុងក្រសួង ស្ថាប័ន។

៣ - ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈអគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ ត្រូវទទួលយកនូវលិខិតបទដ្ឋានគតិយុត្តនានាដើម្បីចងក្រង បោះពុម្ព និងចែកចាយផ្សព្វផ្សាយសៀវភៅរាជកិច្ច លើកលែងតែលិខិតបទដ្ឋានគតិយុត្តណាដែលមានកំហុសមិនអាចធ្វើការចុះផ្សាយបាន ត្រូវបញ្ជូនទៅក្រសួង ស្ថាប័នសាមីដើម្បីធ្វើការកែតម្រូវ រួចបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីវិញដើម្បីចុះផ្សាយឱ្យបានទាន់ពេលវេលា។

៤ - លិខិតបទដ្ឋានគតិយុត្តនានាដែលត្រូវចុះផ្សាយក្នុងសៀវភៅរាជកិច្ចរួមមាន ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ និងប្រកាស។

៥ - លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលបានចងក្រង បោះពុម្ពជាសៀវភៅរាជកិច្ច ត្រូវទុកជាឯកសារផ្លូវការរបស់រដ្ឋ។

៦ - ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈអគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ ត្រូវចែកចាយផ្សព្វផ្សាយសៀវភៅរាជកិច្ចឱ្យបានទូលំទូលាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងប្រទេស។

Scanned with CamScanner

៧ - តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំនិងចៅសង្កាត់ត្រូវទទួលភារកិច្ចដើម្បីធ្វើការផ្សព្វផ្សាយគ្រប់លេខនៃសៀវភៅរាជកិច្ចនៅតាមសាលាឃុំ សង្កាត់។

៨ - ទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចផ្សព្វផ្សាយសៀវភៅរាជកិច្ចដល់សាធារណជន តាមរយៈគេហទំព័ររបស់ទីស្តីការគណៈរដ្ឋមន្ត្រី (http://ocm.gov.kh)។

៩ - គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវដាក់លិខិតស្នើសុំសៀវភៅរាជកិច្ចដោយឥតគិតថ្លៃ តាមនីតិវិធីរដ្ឋបាល មកទីស្តីការគណៈរដ្ឋមន្ត្រី ជារៀងរាល់ឆ្នាំ។

១០ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំផ្តល់ថវិកាដើម្បីបំពេញនូវតម្រូវការក្នុងការចងក្រង បោះពុម្ព និងផ្សព្វផ្សាយសៀវភៅរាជកិច្ចឱ្យបានដល់គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងប្រទេស។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅទូទាំងប្រទេស ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។ Ph

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner